# តារាងសំណើបែងចែកមុខងារក្នុងវិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ រវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

## I. វិស័យអប់រំ

| ល.រ | មុខងារ | ក្រសួងអប់រំ | មន្ទីរអប់រំខេត្ត | រដ្ឋបាលក្រុង ស្រុក |
|---|---|---|---|---|
| | ការគ្រប់គ្រង | គ្រប់គ្រងការអប់រំថ្នាក់ឧត្តមសិក្សា | គ្រប់គ្រងការអប់រំថ្នាក់មធ្យមសិក្សា (វិទ្យាល័យ និងអនុវិទ្យាល័យ) | ក. គ្រប់គ្រងការអប់រំថ្នាក់បឋមសិក្សា<br>ខ. គ្រប់គ្រងការអប់រំកុមារតូច និងអប់រំក្រៅប្រព័ន្ធ |
| **ការបែងចែកមុខងារសម្រាប់គ្រប់គ្រងបឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ** | | | | |
| ១ | គោលនយោបាយ និងផែនការអប់រំជាតិ | រៀបចំគោលនយោបាយ និងផែនការអប់រំជាតិសម្រាប់ថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | | |
| ២ | កម្មវិធីសិក្សា បទដ្ឋាន និងការប្រឡង | រៀបចំកម្មវិធីសិក្សា បទដ្ឋានសម្រាប់ថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | គាំទ្រផ្នែកបច្ចេកទេសសម្រាប់ការរៀបចំការប្រឡង | រៀបចំការប្រឡងសម្រាប់ថ្នាក់បឋមសិក្សា |
| ៣ | ហេដ្ឋារចនាសម្ព័ន្ធ ភស្តុភារ | កំណត់និយាមសម្រាប់ការបង្កើតសាលាថ្មី ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារ បរិក្ខារ | ជួយគាំទ្រ និងត្រួតពិនិត្យលើការអនុវត្តតាមនិយាមដែលបានកំណត់ | - លើកសំណើបង្កើតសាលាបឋមសិក្សា និងមត្តេយ្យសិក្សា<br>- លើកសំណើ និងអនុវត្តកិច្ចលទ្ធកម្ម និងការសាងសង់ ជួសជុល និងថែទាំអគារសាលារៀន |

| | | | | |
|---|---|---|---|---|
| | | | | - ចាត់ចែង និងគ្រប់គ្រងសំភារៈ បរិក្ខា និងចំណាយប្រតិបត្តិរដ្ឋបាល<br>- បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ<br>- |
| ៤ | ការទទួលស្គាល់គុណភាពអប់រំ | វាយតម្លៃការអប់រំថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | ជួយគាំទ្រក្នុងការវាយតម្លៃការអប់រំថ្នាក់បឋមសិក្សា កុមារតូច និងអប់រំក្រៅប្រព័ន្ធ | |
| ៥ | គ្រូ និងបុគ្គលិកអប់រំ | - កំណត់បទដ្ឋាន និងត្រួតពិនិត្យលើការជ្រើសរើស បណ្តុះបណ្តាលគ្រូ ការផ្ទេរគ្រូ និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូ<br>- ផ្ទេរគ្រូ និងបុគ្គលិកអប់រំពីខេត្តមួយទៅខេត្តមួយ | - រៀបចំការប្រឡងជ្រើសរើសគ្រូ<br>- បណ្តុះបណ្តាលគ្រូ និងអភិវឌ្ឍវិជ្ជាជីវៈគ្រូ<br>- ផ្ទេរគ្រូពីក្រុង ស្រុកមួយ ទៅក្រុង ស្រុកមួយនៅក្នុងដែនសមត្ថកិច្ចនៃខេត្តសាមី | - រៀបចំផែនការជ្រើសរើសគ្រូ និងបុគ្គលិកអប់រំកម្រិតបឋមសិក្សា និងអប់រំកុមារតូច<br>- គ្រប់គ្រងគ្រូ និងបុគ្គលិកអប់រំដែលបានផ្ទេរទៅឲ្យក្រុង ស្រុក<br>- ការផ្ទេរគ្រូ ឬបុគ្គលិកអប់រំនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក |
| ៦ | ការអនុញ្ញាតលើការផ្តល់សេវាអប់រំ | | | - អនុញ្ញាតលើការផ្តល់សេវាអប់រំថ្នាក់បឋមសិក្សា សេវាអប់រំកុមារតូច និងអប់រំក្រៅប្រព័ន្ធ |